ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សីលធម៌
# នៅក្នុងសង្គមខ្មែរ

បង្រៀនដោយ៖ សាស្ត្រាចារ្យ តង់ ភូមីកា
រៀបរៀងដោយ៖ និស្សិតក្រុមទី៦ *(RULE)*

# មាតិកា


**អារម្ភកថា**……………………………………………………………………i
**សេចក្ដីថ្លែងអំណរគុណ**……………………………………………………………ii
**មាតិកា**……………………………………………………………………iii
**សេចក្ដីផ្ដើម**……………………………………………………………………iv
**១. ដើមកំណើតនៃសីលធម៌**……………………………………………………១
**២. និយមន័យសីលធម៌**……………………………………………………………២
ក. សីលធម៌ក្នុងសាលារៀន……………………………………………………៣
ខ. សីលធម៌អ្នកបើកបរ……………………………………………………………៤
គ. សីលធម៌ក្នុងពេលបរិភោគ……………………………………………………៥
ឃ. សីលធម៌ពេលធ្វើដំណើរ……………………………………………………៦
ង. សីលធម៌នៅទីប្រជុំជន…………………………………………………………៦
**៣. គោលការណ៍សីលធម៌នៅក្នុងសង្គមខ្មែរ**…………………………………៧
**៤. ប្រភេទផ្សេងៗនៃសីលធម៌**……………………………………………………៨
ក. សីលធម៌ចំពោះខ្លួនឯង…………………………………………………………៨
ខ. សីលធម៌ចំពោះគ្រួសារ…………………………………………………………៨
គ. សីលធម៌ចំពោះអ្នកដទៃ………………………………………………………៨
ឃ. សីលធម៌ក្នុងវិជ្ជាជីវៈ……………………………………………………………៩
ង. សីលធម៌ចំពោះសង្គមជាតិ……………………………………………………៩
ច. សីលធម៌ចំពោះពិភពលោក……………………………………………………១០
**៥. មូលហេតុនៃការស្រុតចុះនៃតម្លៃសីលធម៌ក្នុងសង្គមខ្មែរ**……………………១០
ក. កត្តាមនោសញ្ចេតនាបាក់ផ្នត់…………………………………………………១១
ខ. ការបាត់បង់ជំនឿលើខ្លួនឯង…………………………………………………១១
គ. សង្គ្រាមអូសបន្លាយ……………………………………………………………១១
ឃ. កត្តាមហិច្ឆតា……………………………………………………………………១១
ង. កត្តាទ្រព្យសម្បត្តិ…………………………………………………………………១២
ច. កត្តាការហូរចូលនៃវប្បធម៌បរទេស……………………………………………១២
ឆ. កត្តាច្បាប់…………………………………………………………………………១២
ជ. កត្តាគ្រឿងញៀន…………………………………………………………………១៣
ឈ. កត្តាការអប់រំធ្លាក់ចុះ……………………………………………………………១៣

**៦. ផលវិបាកដែលបណ្តាលពីការធ្លាក់ចុះនៃសីលធម៌**..........................១៣
ក. ការបាត់បង់នូវសេចក្តីសុខខាងផ្លូវចិត្ត..........................១៣
ខ. បាត់បង់គុណតម្លៃជាមនុស្ស..........................១៣
គ. បែកបាក់សាមគ្គី..........................១៤
ឃ. អសន្តិសុខសង្គម..........................១៤
ង. សង្គ្រាម..........................១៤
**៧. ដំណោះស្រាយខ្លះៗក្នុងការលើកកម្ពស់សីលធម៌**..........................១៤
ក. ផ្តើមពីបុគ្គលខ្លួនឯង..........................១៥
ខ. ការស្គាល់ពីគុណតម្លៃខ្លួនឯងនឹងអ្នកដទៃ..........................១៥
គ. លើកទឹកចិត្តសកម្មភាពសីលធម៌..........................១៥
ឃ. បង្កើនការអប់រំផ្នែកសីលធម៌..........................១៦
ង. ការបណ្តុះគំនិតជាតិនិយម..........................១៦
ច. សន្តិភាពក្នុងចិត្ត..........................១៦
ឆ. រឹតបន្តឹងច្បាប់..........................១៧
**៨. សេចក្តីសន្និដ្ឋាន និង អនុសាសន៍**..........................១៧
ក. សេចក្តីសន្និដ្ឋាន..........................១៧
ខ. អនុសាសន៍..........................១៨
**ឯកសារយោង**

# សេចក្តីផ្តើម

តើសីលធម៌ជាអ្វី? តើសីលធម៌កើតចេញពីបុព្វហេតុអ្វីខ្លះ? ហេតុអ្វីបានជាគេត្រូវការសីលធម៌? ចុះហេតុអ្វីបានជាសីលធម៌មានការធ្លាក់ចុះ? តើយើងត្រូវស្រោចស្រង់សីលធម៌ឡើងវិញដោយរបៀបណា?

កាលណានិយាយពីសីលធម៌ យើងដឹងហើយថាសីលធម៌គឺជាធម៌របស់សត្វលោក ឬ ជាកិរិយាមាយាទ សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឲ្យជៀសវាងអំពើអាក្រក់ ហើយប្រព្រឹត្តតែអំពើល្អជានិច្ច។ សីលធម៌អាចស្តែង ចេញតាមរយៈ សុភាវៈធម៌ គឺការដើរ, ដេក, ឈរ, អង្គុយសមរម្យសុភាពរៀបសារត្រឹមត្រូវ សុជីវធម៌គឺការ រស់នៅល្អ ចំពោះសណ្តាប់ធ្នាប់ ការដឹងប្រមាណក្នុងកិច្ចការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។

គ្មានបុគ្គលណាអាចរស់នៅតែឯកឯងបានឡើយ គឺគេត្រូវរស់នៅជាក្រុមជាសង្គម ហើយដើម្បីរស់នៅក្នុងសង្គមបានលុះត្រាសមាជិកម្នាក់ៗគោរពច្បាប់វិន័យ សិទ្ធិគ្នា និងមានសីលធម៌ចំពោះគ្នាទៅវិញទៅមក។ ព្រះពុទ្ធសាសនាបានអោយតម្លៃទៅលើសីលធម៌យ៉ាងខ្លាំង ទ្រង់បានសម្តែងថារវាងសីលធម៌និងបញ្ញា គឺសីលធម៌ ប្រសើរជាងមិនខុសអ្វីដែលបុគ្គលម្នាក់មានបញ្ញាក្នុងការប្រើប្រាស់ដាវឬអាវុធ តែបើគ្មានសីលធម៌គ្រប់ដណ្តប់ទេ គេអាចនឹងយកដាវឬអាវុធទៅកាប់សម្លាប់មនុស្សដោយគ្មានធម៌មេត្តា។ ម្យ៉ាងវិញទៀតយើងឃើញថានៅក្នុងតម្រូវការ ម៉ាស្លូ ក្រៅអំពីចំណីអាហារ ជម្រក ការស្រលាញ់ មនុស្សត្រូវការការអោយតម្លៃនិងការគោរពដែលយើងហៅថាសីលធម៌ក្នុងការអោយតម្លៃគ្នាទៅវិញទៅមក។

ទន្ទឹមគ្នានេះដែរយើងបានឃើញថាសីលធម៌ពេលខ្លះមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយយើងក៏ត្រូវការមធ្យោបាយផ្សេងៗដើម្បីស្តារសីលធម៌អោយងើបឡើងវិញ តែមុននឹងបង្ហាញឬស្វែងរកមធ្យោបាយទាំងនេះ យើងត្រូវយល់ដឹងផងដែរអំពីបុព្វហេតុដែលនាំអោយមានសីលធម៌កើតឡើង និងបុព្វហេតុដែលធ្វើអោយសីលធម៌ធ្លាក់ចុះ។

# សីលធម៌នៅក្នុងសង្គមខ្មែរ

## ១. ដើមកំណើតនៃសីលធម៌




សីលធម៌មានមក តាំងពីមនុស្សយើងចេះគិតពិចារណា ( Homo មនុស្ស - Sapiens គិតពិចារណា ) គឺតាំងពីចេញពីពួកព្រីម៉ាត(primate)មកម៉្លេះ គឺចាប់ពីបីទៅបួនលានឆ្នាំមកហើយ។ កាលនៅជាសត្វនៅឡើយ "សត្វមនុស្ស" មិនទាន់ចេះកំណត់ថាអ្វីល្អ អ្វីអាក្រក់នៅឡើយនោះទេ គឺគិតតែប្រខាំគ្នាដណ្តើមចំណីគ្នាស៊ី អ្នកមានកំលាំងគឺអ្នកឈ្នះ។ លុះក្រោយមកទៀត "សត្វមនុស្ស" បានចេះងើបដើរដោយជើងទាំងពីរខាង ក្រោយមកខួរក្បាលមានការវិវត្តឈានទៅចេះគិតខុសត្រូវ ស្គាល់ល្អអាក្រក់ កំណត់បទដ្ឋានរស់នៅបានសមតាមកាលៈទេសៈនៅក្នុងសម្ព័ន្ធ បង្កើតបានច្បាប់សីលធម៌សំរាប់ប្រតិបត្តិតាម។ គេអាចប្រដូចសីលធម៌រស់នៅក្នុងពេលនោះទៅនឹងក្បួន ឬ ច្បាប់ល្បែងផ្សេងៗ។ ឧទាហរណ៍ៈ ល្បែងចត្រង្គ ល្បែងបាល់ទាត់ ។ល។ អ្នកប្រកួតត្រូវតែគោរពច្បាប់ ដើម្បីឲ្យល្បែងប្រព្រឹត្តទៅបានត្រឹមត្រូវ។ កុលសម្ព័ន្ធខ្មែរដែលបានមកតាំងទីលំនៅដ្ឋាននៅលើទឹកដីកម្ពុជាសព្វថ្ងៃ ក៏មានសីលធម៌រស់នៅតាមសម័យកាលនោះដែរ។ បើក្រឡេកមើលជនជាតិភាគតិចវិញ គេរស់នៅជាកុលសម្ព័ន្ធដូចជនជាតិខ្មែរយើងដែរ។ តើកុលសម្ព័ន្ធនោះ មានសីលធម៌រស់នៅយ៉ាងណា? ទោះបីជាគេល្ងង់ខ្លៅយ៉ាងណាក៏ដោយក៏គេមានចិត្តទៀងត្រង់មិនភូតកុហកគ្នាដែរ ។

ផ្ទុយទៅវិញ ប្រសិនបើជាមាននរណាប្រព្រឹត្តិអំពើមួយ ខុសវិន័យកំណត់នោះ មេកន្ទ្រាញព្រមទាំងកុលសម្ព័ន្ធទាំងមូលថ្កោលទោសទៅតាមកំហុស។ ទង្វើនេះគឺកុលសម្ព័ន្ធមានបំណងប្រាថ្នាចង់ឲ្យសមាជិករបស់ខ្លួនរស់នៅបានត្រឹមត្រូវតាមគន្លងសីលធម៌តែប៉ុណ្ណោះ។ ការវិវត្តន៍កុលសម្ព័ន្ធទៅតាមសីលធម៌ គឺជាលទ្ធផលនៃឆន្ទៈរួមរបស់មនុស្ស ដែលប្រយុទ្ធនឹងធម្មជាតិ ដើម្បីឲ្យខ្លួនចេញផុតពីច្បាប់ព្រៃ ហើយអាចកសាងសង្គមមនុស្សមួយ មានសីលធម៌មានច្បាប់ទំលាប់ជាមនុស្សជាតិ ។ កាលមនុស្សលោកមិនទាន់ចេញផុតពីសម័យបុរេប្រវត្តិយើងសង្កេតឃើញថា សីលធម៌ដែលបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ទៅតាមពាក្យសំដីនិយាយតៗគ្នាមិនទាន់មានចារទុក ឬឆ្លាក់ថ្មជាសំគាល់នៅឡើយទេ ។

លុះមនុស្សបានចេញផុតពីសម័យបុរេប្រវត្តិ កាលពី ៣២០០ឆ្នាំ មុន គ.ស គឺជំណាលគ្នា និង អក្សរដែរនោះ មនុស្សប្រព្រឹត្តទៅតាមសីលធម៌សាសនា ។ ចិត្តវិទូជំនាន់នោះបង្វែរចិត្តមនុស្សឲ្យខ្លបខ្លាចអំណាច ឬ កំលាំងធម្មជាតិមានរន្ទះ ខ្យល់សង្ឃរា ជាដើម ដោយណែនាំឲ្យយល់និង ជឿស្លុងថាធម្មជាតិទាំងមូល គឺជាអាទិទេពជាអ្នកបង្កើត។ អាទិទេពមិនគ្រាន់តែជាអ្នកបង្កើតមនុស្សប្រុសស្រីលើផែនដីនេះទេ ថែមទាំងបង្កើតទេវតាដែលចែកជាពីរក្រុមៈ ក្រុមមួយជួយថែរក្សាជួយជំរុងចម្រើន និង ក្រុមបំផ្លាញ កាលណាមនុស្សមិនគោរពតាមបទដ្ឋានសីលធម៌ ឬមិនបាននឹកនាធ្វើពិធីបូជាផ្សេងៗ។ មិនតែប៉ុណ្ណោះ អាទិទេពបង្កើតក្រុមទេវតាមួយទៀត ចាំតែកាត់សេចក្តីខុសត្រូវនៅពេលក្រោយមនុស្សធ្វើមរណកាល។ នៅប្រទេសអេស៊ីប អំឡុងកាលជាងប្រាំពាន់មុនគ.សអ្នកដឹកនាំសាសនាបានអប់រំប្រជាជនឲ្យប្រព្រឹត្តសីលធម៌ ដោយយកនាមអាទិភាពថា ជាអ្នកបង្គាប់ ។ គេបានបង្កើតចៅក្រម ៤២ អង្គអមស្តេចយមរាជដែលមានឈ្មោះអូស៊ីរីស ដើម្បីសួរព្រលឹងអ្នកស្លាប់។

អាស្រ័យហេតុនេះមនុស្សតែងតែភ័យខ្លាច ហើយខិតខំកសាងខ្លួនដោយគោរពគោលការណ៍សីលធម៌សង្គម និង សាសនា។ នៅប្រទេសកម្ពុជាយើង ជំនឿសាសនាមានជាហូរហែរកន្លងមកមានព្រាហ្មសាសនា និង ពុទ្ធសាសនាជាដើម។ សីលធម៌ព្រះពុទ្ធក៏មានប្រហាក់ប្រហែលគ្នា និងសីលធម៌នៃសាសនាដទៃ។ យើងគួរពិចារណាលើពុទ្ធោវាទ ដែលមានជាង ៥០០ឆ្នាំ មុនគ.ស ។ ត្បិតតែសីលធម៌របស់ព្រះពុទ្ធមានមកជាយូរហើយក៏ពិតមែន តែមានតម្លៃអមតៈសំរាប់អ្នកកាន់ព្រះពុទ្ធសាសនាប្រតិបត្តិតាមបានគ្រប់ពេលវេលា។ ជាបន្តបន្ទាប់មកមានព្រឹទ្ធាចារ្យចេះ តែបន្តទូន្មានកូនចៅឲ្យ យល់ដឹងពីសីលធម៌រៀងរហូតមកដើម្បីឲ្យសង្គម នីមួយៗ មានច្បាប់សីលធម៌អនុវត្តត្រឹមត្រូវចៀសវាង កុំឲ្យមនុស្សធ្លាក់ ទៅជាសត្វតិរិច្ឆានប្រកាប់ប្រចាក់គ្នាឥតត្រាប្រណីឲ្យមនុស្សដឹងល្អ ដឹងអាក្រក់ ដឹងខុស ដឹងត្រូវ ឲ្យមនុស្សជាតិរស់រានមានជីវិតជាយូរអង្វែងតទៅ។

## ២. និយមន័យសីលធម៌

ជាជំហានទី១ ជាបទទី១ ដែលគួរដល់ការសិក្សាគឺគួររៀនសូត្រឲ្យចេះដឹង ហើយត្រូវធ្វើតាមឲ្យបានល្អជាទីបំផុត។ កាលបើយើងប្រតិបត្តិតាមសីលធម៌បានហើយប្រទេសយើងនឹងមានសេចក្តីសុខសន្តិភាពមិនមានអំពើសម្លាប់គ្នា មិនលួចឆក់ប្លន់យកទ្រព្យគ្នាមិនប្រព្រឹត្តអានាចារលើប្តីប្រពន្ធកូនចៅ អ្នកដទៃ មិនកុហកបោកប្រាស់គ្នា មិនផឹកស្រវឹង មិនសេពគ្រឿងញៀន។

- **សីលធម៌** គឺជាមារយាទល្អក្នុងការប្រព្រឹត្ត ឬជារបៀបនៃការរស់នៅ ទាំងជាផ្នែកផ្ទាល់ខ្លួន និង ជាផ្នែកទំនាក់ទំនងជាមួយសង្គមជុំវិញដោយកាយវាចា រហូតដល់ការងារចិញ្ចឹមជីវិត។[1]

[1] ង៉ែត សារឿន, រៀបរៀង, ទស្សនវិជ្ជាសីលធម៌ៈ សីលធម៌ អប់រំ (ភ្នំពេញៈ ពុទ្ធិកសាកលវិទ្យាល័យសីហមុនីរាជា,២០១១)។

- **សីលធម៌** គឺជាការប្រព្រឹត្តទៅដើម្បីធ្វើ ឲ្យការរស់នៅនោះឯង មានអំណោយ ផលដល់ការបដិបត្តិផ្សេងៗដែលប្រព្រឹត្តទៅដើម្បីចូលដល់ទីបំផុតនៃសេចក្តីល្អគឺជាឧត្តមគតិរបស់មនុស្សក្នុងសង្គម។[2]
- **សីលធម៌** គឺជាធម៌របស់សត្វលោក ឬ ជាកិរិយាមារយាទ សណ្តាប់ធ្នាប់ ដំបូន្មាន ដែលនាំឲ្យជៀសវាង អំពើអាក្រក់ ហើយប្រព្រឹត្តតែអំពើល្អជានិច្ច។[3]

## *ក. សីលធម៌ក្នុងសាលារៀន*

នៅតាមសាលារៀន សិស្សានុសិស្សទាំងឡាយ ត្រូវជួយថែរក្សាសោភ័ណភាពសាលាឲ្យបានល្អប្រសើរឡើង នាំគ្នាបោសសំអាតថ្នាក់រៀន ទីធ្លាសាលាជូតលាងតុកៅអីរៀបចំទុកដាក់ឲ្យមានរបៀបរៀបរយ មានសណ្តាប់ធ្នាប់ល្អ ហើយ ដាច់ខាតសិស្សានុសិស្សមិនត្រូវធ្វើនូវទង្វើទាំងឡាយណាដែលធ្វើអោយខូចខាតទ្រព្យសម្បត្តិរបស់រដ្ឋ ឬ សាលាឡើយ។

❖ **ទង្វើដែលសិស្សានុសិស្សមិនគួរគប្បីប្រព្រឹត្តិនៅសាលារៀន ៖**

- មិនត្រូវយកទឹកលុប ប៊ិច ដីស ហ្វឺត ឬរបស់អ្វីៗសរសេរអក្សរ គូររូបលេងលើតុកៅអី និងតាមជញ្ជាំងសាលាឡើយ។
- មិនត្រូវយកកំណាត់ឈើ ឬវត្ថុអ្វីៗ វាយដំលើតុកៅអី ប្រគំធ្វើភ្លេងលេង ដែលជាហេតុបង្កឲ្យមានការបែកបាក់។
- មិនត្រូវឡើងជាន់ទន្រ្ទាំលើតុកៅអី ឬ ប្រលែងគ្នារត់ជាន់តុកៅអី ដែលជាហេតុនាំមកនូវគ្រោះថ្នាក់ និង ខូចខាត។
- មិនត្រូវហែកក្រដាស់ ឬ កាកសំណល់ញាត់ចូលក្នុងថតតុ
- មិនត្រូវគោងទ្វារ ឬ បង្អួចយោលលេងចុះឡើង ដែលជាហេតុធ្វើឲ្យដាច់ត្រចៀកទ្វារ ឬបង្អួច
- មិនត្រូវយកដំថ្ម ឬកំណាត់ឈើគប់ទៅលើដំបូលសាលា ដែលនាំឲ្យបែកក្បឿង
- មិនត្រូវចោលកាកសំណល់ក្នុងថ្នាក់រៀន និង ទីធ្លាសាលាដោយឥតរបៀបឡើយគប្បីចោលក្នុងធុងសំរាម។

នៅក្នុងកិច្ចថែរក្សាសាលាឲ្យបានល្អ គឺបិតនៅលើលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនេះឯង។ ការជួយថែរក្សាសម្បត្តិសាលារៀនក៏ដូចជាការជួយថែរក្សាការពារជាតិយើងដែរ។ សាលារៀនជាថ្នាលបណ្តុះបណ្តាលនូវចំណេះដឹង និងសមត្ថភាពក្នុងការងារផ្សេងៗ ដូច្នេះយើងត្រូវថែទាំនូវសមិទ្ធិផលដែលមានហើយឲ្យគង់វង្សបានយូរអង្វែង កុំឲ្យដូចបុរាណសុភាសិតលោកថា “ដៃភ្លើង ជើងមាន់” ប្រើប្រាស់របស់ណា របស់នោះខូចខាត។

[2] សៀវភៅ <<សីលធម៌សំខាន់សំរាប់មនុស្ស>> រៀបរៀងដោយ បណ្ឌិត ឌិត ប៉ែន ព.ស ២៥៥១។

[3] វចនានុក្រមខ្មែរ របស់សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ដែលមាន១៨៨៨ទំព័រ។

## ២. សីលធម៌អ្នកបើកបរ



អ្នកបើកបរត្រូវគោរពច្បាប់ចរាចរណ៍ និងបើកបរដោយប្រុងប្រយ័ត្តជានិច្ច មានសតិស្មារតីគ្រប់គ្រងចង្កូតឲ្យបានល្អជាទីបំផុតកុំធ្វេសប្រហែលឲ្យសោះឡើយ ហើយចូរចងចាំទុកក្នុងចិត្តថាជីវិតមនុស្ស មិនមានដាក់លក់នៅលើទីផ្សារទេ។

- **អ្នកបើកបរ គប្បីមានសីលធម៌ដូចខាងក្រោម ៖**
  - កុំជក់បារីពេលកំពុងបើកបរ
  - កុំទទួលទានអាហារពេលកំពុងបើកបរ
  - កន្លែងមានដីហុយ ឬផ្លូវទឹកភ្លៀងជក់ គប្បីបន្ថយល្បឿនយានយន្តឲ្យសមល្មម ដើម្បីកុំឲ្យហុយដីខ្លាំង ឬខ្ទាយទឹកភក់ប្រឡាក់អ្នកដទៃ។
  - ពេលជិតដល់ទីប្រជុំជន គប្បីបន្ថយល្បឿនយានយន្តឲ្យសមរម្យ ដែលអ្នកដទៃអាចទទួលបាន
  - កុំចុចស៊ីផ្លេ កន្លែងមន្ទីរពេទ្យ ឬ សាលារៀន ដែលជាការធ្វើឲ្យរំខាន
  - មិនត្រូវប្រើភ្លើងហ្វាឲ្យប៉ះពាល់ដល់អ្នកដទៃ និងគប្បីអត់ឱនអធ្យាស្រ័យចំពោះការខុសឆ្គងរបស់អ្នកថ្មើរជើង ឬ អ្នកបើកបរដូចគ្នា។
  - មិនត្រូវផ្ទុកលើសកំណត់ ព្រោះវានាំអោយមានគ្រោះថ្នាក់
  - មានសីលធម៌នៅក្នុងខ្លួន ចេះអត់ឱន ចេះអធ្យាស្រ័យ ឲ្យគ្នាទៅវិញទៅមក គឺជាគុណធម៌មួយ ដែលធ្វើឲ្យយើងទទួលបាននូវការរាប់អាន សេចក្តីសុខ និងសេចក្តីថ្លៃថ្នូរ។





❖ **លក្ខណៈរបស់អ្នកមិនគួរបើកបរ ៖**

- មិនបានរៀនច្បាប់បើកបរ ហើយប្រថុយបើកបរដោយខ្លួនឯង
- ផឹកគ្រឿងស្រវឹងច្រើន
- សេពគ្រឿងញៀន
- អត់ងងុយខ្លាំង
- ហេវហត់ខ្លាំង
- ខឹងក្រោធខ្លាំង
- អន្ទះសារតក់ក្រហល់ចង់ឆាប ចង់ដល់ហួសហេតុ......។

## គ. *សីលធម៌ក្នុងពេលបរិភោគ*



ពេលទទួលទានអាហារជុំគ្នាជាមួយគ្រួសារ ឬជាមួយភ្ញៀវ យើងត្រូវរក្សាសណ្តាប់ធ្នាប់ឲ្យមានរបៀបរៀបរយ និង មានអនាម័យក្នុងការបរិភោគ។ កាលបើយើងបរិភោគមានរបៀបរៀបរយ ត្រឹមត្រូវមានអនាម័យល្អ ធ្វើឲ្យអ្នកបរិភោគជាមួយយើង គេមិនខ្ពើមរអើមតែបើយើងបរិភោគឥតរបៀប និងអត់អនាម័យទេ ធ្វើឲ្យអ្នកទទួលទានអាហារជាមួយយើងគេរង្កៀសក្នុងចិត្ត ឬ ខ្ពើម។ ភារកិច្ចពេលទទួលទានអាហាររួចហើយ គឺបោសជូតលាងរៀបចំទុកដាក់នូវសម្ភារៈ។

❖ **ប្រការដែលគួរជៀសវាងពេលបរិភោគ ៖**

- ទាញយកចានស្លាបព្រា លាន់សូររ៉ូងរ៉ាង
- វែកស្លាបព្រាចាន មិនស្អាតយកទៅដួសដាក់ម្ហូបអាហារ

- ដៃមិនស្អាតចាប់រំលែក ចំណីអាហារផ្ទាល់ដៃ
- ដួសបាយសម្លពេញចាន ពេញស្លាបពេក លើមកកំពប់ស្រក់ទ្បិករទ្បាក់
- និយាយទាំងបាយនៅពេញមាត់ ជ្រុះគ្រាប់បាយចេញពីមាត់
- ខ្ទាក់ឆ្អឹងម្ហូបអាហារឥតរបៀប
- លស់គ្រាប់បាយហៀរតាមមាត់ចាន
- កោសចានលឺៗ
- ញើសសំបោរខាកស្តោះពេលកំពុងបរិភោគ
- កណ្តាស់ឈ្លក់មិនបែរមុខចេញ ខ្ជាយទឹកមាត់ចូលបាយសម្ល
- កំសៀវ ប៉ាន់ កែវ ផ្តិលកខ្វក់
- ចាក់ធ្មេញមិនបាំងមាត់
- មិនត្រូវឈ្លោះគ្នាក្នុងពេលបរិភោគបាយ ឬ មិនត្រូវលើក វិភាគរឿងដែលនាំអោយកើតជម្លោះក្នុងពេលបរិភោគបណ្តាលអោយខូចបរិយាកាសក្នុងការបរិភោគនេះទេ.......។

## ឃ. *សីលធម៌ពេលធ្វើដំណើរ*

- ពេលយើងធ្វើដំណើរជិះទ្បាន ម៉ូតូតាមផ្លូវថ្នល់ ជាផ្លូវសាធារណៈយើងមិនត្រូវខាកស្តោះទឹកមាត់ដាក់លើថ្នល់ ឬចោលកាកសំណល់ផ្តេសផ្តាសឡើយ ត្រូវរក្សាសេចក្តីថ្លៃថ្នូរ និងភាពស្អាតស្អំឲ្យប្រទេសយើង។
- ពេលកំពុងធ្វើដំណើរនោះ បើមានការទទួលទានចំណីអាហារតាមរថយន្ត ដាច់ខាតកុំចោលកាកសំណល់តាមមាត់បង្អួចទ្បាន ត្រូវវេចខ្ចប់កាកសំណល់នោះឲ្យបានល្អ ចាំពេលដល់ធុងសំរាម ឬកន្លែងដែលសមគួរនឹងចោលបានសឹមចោលចុះ នេះទើបជាការប្រពៃ។ ប្រសិនបើយើងចោលសំរាមឥតរបៀប ដូចជាចោលតាមមាត់បង្អួចទ្បាននោះជាដើមវាធ្វើឲ្យប៉ះពាល់ដល់អ្នកធ្វើដំណើរដូចគ្នា និង ប៉ះពាល់ដល់អ្នករស់នៅតាមដងវិថី។
- ម្យ៉ាងទៀត ការចោលកាកសំណល់មិនបានល្អនេះ វាធ្វើឲ្យថ្នល់ពាសពេញទៅដោយសំរាម មានថង់ប្លាសស្ទិចប៉ើងព្រោងព្រាតពេញតែថ្នល់ មានក្លិនមិនល្អ។ ការធ្វើបែបនេះមិនល្អទេ វាធ្វើឲ្យប្រទេសអាប់ឱន ជាពិសេសធ្វើឲ្យខូចបរិស្ថាន និងជះឥទ្ធិពលមិនល្អឲ្យយើងគ្រប់គ្នា។

## ង. *សីលធម៌នៅទីប្រជុំជន*

- នៅទីកន្លែងប្រជុំជនមានទីក្រុង ខេត្ត និងផ្សារយើងជាប្រជាពលរដ្ឋគប្បីជួយថែរក្សាសណ្តាប់ធ្នាប់មានសុជីវធម៌ក្នុងការធ្វើដំណើរ មិនដើរប្រជ្រៀតប៉ះពាល់គ្នា ឬ ជិះយានយន្តបើកបរដោយឥតគោរពច្បាប់ចរាចរណ៍នោះឡើយ។

- ម្យ៉ាងទៀត ពេលយើងធ្វើដំណើរឆ្លងកាត់ទីក្រុង ខេត្ត ផ្សារ និងដើរកំសាន្តតាមដំបន់ទេសចរណ៍ផ្សេងៗក្តី យើងគប្បីជួយសម្រួលខាងផ្នែកសណ្តាប់ធ្នាប់ និងជួយសំអាតបរិស្ថាននៅកន្លែងនោះឲ្យបានស្អាតល្អ កុំចោលសំរាមក្រៅធុងសំរាមផ្តេសផ្តាសឡើយ។
- ក្បួនសីលធម៌ គឺនៅលើយើងម្នាក់ៗ ហ្នឹងហើយដែលជាម្ចាស់ការរៀងៗខ្លួនក្នុងការថែរក្សាបរិស្ថានឲ្យបានល្អនោះ។

## ៣. គោលការណ៍សីលធម៌នៅក្នុងសង្គមខ្មែរ

ទស្សនៈវិជ្ជាសីលធម៌ ជាការសិក្សាពីអ្វីដែលត្រូវ ឬ ខុសនៅក្នុងទង្វើរបស់មនុស្ស និងជាការកែប្រែជីវិតប្រកបដោយកុសល។ វាកំណត់នូវការប្រព្រឹត្តល្អ ឬមិនល្អ ដែលការសិក្សាសំខាន់ទៅលើគោលការណ៍សីលធម៌គឺត្រូវបានពិនិត្យ និង អនុវត្តយ៉ាងម៉ត់ចត់។ ផ្អែកលើមូលដ្ឋាននេះ យើងដឹងថាអាកប្បកិរិយារបស់យើងម្នាក់ៗប្រកបដោយសីលធម៌ត្រឹមត្រូវ មានគុណធម៌ តើត្រូវធ្វើដូចម្តេចខ្លះ? ហេតុអ្វីបានជាយើងត្រូវសិក្សាពីគោលការណ៍សីលធម៌?

ទស្សនៈវិជ្ជាសីលធម៌ ជាមុខវិជ្ជាចាំបាច់នៅក្នុងសង្គម និង នៅក្នុងកម្មវិធីសិក្សារបស់និស្សិតមហាវិទ្យាល័យ។ ការសិក្សាពីទស្សនៈវិជ្ជាសីលធម៌ គឺបង្ហាញពីតម្លៃ ដែលផ្តល់ដោយអ្នកអប់រំនានា ក្នុងគោលបំណងអភិវឌ្ឍន៍មនុស្សឲ្យក្លាយជាមនុស្សល្អ។ ផ្ទុយមកវិញ បើគ្មានមុខវិជ្ជានេះទេមានន័យថា ផលិតមនុស្សដែលពុទ្ធិរបស់គេនឹងយកទៅប្រើប្រាស់សំរាប់គោលបំណងអាក្រក់ អាត្មានិយម។ សីលធម៌ គឺជាធម្មជាតិមួយសំរាប់មនុស្ស ដើម្បីទាក់ទងគ្នាទៅវិញទៅមក។ ប៉ុន្តែការចងភ្ជាប់គ្នាទៅវិញទៅមក ត្រូវប្រតិបត្តិតាមគោលការណ៍សីលធម៌ ឬបទដ្ឋានសីលធម៌ផ្សេងៗ។ ដូចនេះក្នុងសង្គមខ្មែរ បើគ្មានគោលការណ៍សីលធម៌ទេ វប្បធម៌ អរិយធម៌ និង អត្តិភាពរបស់មនុស្សម្នាក់ៗត្រូវបានគំរាមកំហែង។ ចំពោះហេតុផលនេះ គឺជាកត្តាចាំបាច់ដែលបុគ្គលម្នាក់ៗត្រូវបានបង្ហាញ និង សិក្សាពីទស្សនៈវិជ្ជាសីលធម៌។

## ៤. ប្រភេទផ្សេងៗនៃសីលធម៌

តាមន័យទូទៅ សីលធម៌សំគាល់នូវទ្រឹស្តី និងពាក្យទូន្មានទាំងឡាយណាដែលដឹកនាំទៅរកផ្លូវល្អ និង ជៀសវាងផ្លូវអាក្រក់ សម្រាប់ការរស់នៅ។ តាមន័យពិសេស សីលធម៌សំគាល់ការអប់រំតាមផ្លូវចិត្តឲ្យបានប្រសើរ។ ម្យ៉ាងទៀតក្នុងការរស់នៅប្រចាំថ្ងៃដើម្បីឲ្យខ្លួនយើងក្លាយជាបុគ្គលដែលមាន ប្រយោជន៍នៅក្នុងសង្គម យើងត្រូវមានសីលធម៌ដូចតទៅ ៖

### ក. សីលធម៌ចំពោះខ្លួនឯង

- ដឹងខុសត្រូវ
- ស្គាល់ល្អស្គាល់អាក្រក់
- តាំងខ្លួនជាម្ចាស់ចិត្តរបស់ខ្លួន
- ទទួលខុសត្រូវនឹងអំពើរបស់ខ្លួន
- ក្លាហានក្នុងផ្លូវត្រូវ
- ហ៊ានទទួលខុសត្រូវនឹងទង្វើរបស់ខ្លួន ។

### ខ. សីលធម៌ចំពោះគ្រួសារ

*សីលធម៌ឪពុកម្ដាយចំពោះកូនគឺ ៖*

- ខិតខំចិញ្ចឹមកូនដោយពុំនឹកដល់ការសងគុណតបវិញឡើយ
- ត្រូវធ្វើឲ្យកូនមានភាពសុខដុម
- ស្រឡាញ់កូនស្មើៗគ្នា
- អប់រំកូនជាប្រចាំឲ្យក្លាយជាពលរដ្ឋល្អ
- ត្រូវជាទីទំនុកចិត្តរបស់កូន
- រៀបការ ចែកទ្រព្យសម្បត្តិ និង ឧបត្ថម្ភឲ្យកូនរៀនសូត្រ ។

*សីលធម៌កូនចំពោះឪពុកម្ដាយ ៖*

- ត្រូវគោរពតបស្នងសងគុណនិងចិញ្ចឹមបីបាច់លោក ដោយបច្ច័យបួនឲ្យបានល្អ។
- ត្រូវចេះថែរក្សាវង្សត្រកូលនិងលើកតំកើងកិត្តិយសឲ្យបានល្អព្រមទាំងខិតខំរៀនសូត្រដើម្បីអនាគតខ្លួន និងគ្រួសារ។
- ត្រូវស្ដាប់ដំបូន្មានលោកទាំងពីរ ជួយធ្វើការងារគ្រប់យ៉ាងរបស់លោកនិងថែរក្សា ទ្រព្យសម្បត្តិដែលលោកផ្ដល់ឲ្យយើង។
- ប្រកាន់ឥរិយាបថឲ្យត្រឹមត្រូវចំពោះលោកទាំងពីរកុំញាក់មុខញាក់មាត់ដាក់ ឬ ធ្វើអាកប្បកិរិយាមិនសមគប្បីណាមួយ ដោយកាយក្ដីវាចាក្ដី... ។

### គ. សីលធម៌ចំពោះអ្នកដទៃ

- គោរពសិទ្ធិអ្នកដទៃ
- មិនធ្វើឲ្យអ្នកដទៃឈឺចាប់
- មិនបង្កមហន្តរាយ ឬ អសុវត្ថិភាពដល់អ្នកដទៃ

- ជួយសង្គ្រោះអ្នកដទៃពេលមានទុកលំបាក
- មិនបោកប្រាស់កេងប្រវញ្ច ប្រកបរបរសុចរិត

**ឃ. សីលធម៌ក្នុងវិជ្ជាជីវៈ:**

- មានមនសិការចំពោះការងារ
- រកស៊ីតាមសមត្ថភាពរបស់ខ្លួន
- រកស៊ីតាមសម្មាអាជីវោ (មិនលួច ប្លន់ ឬ កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ)
- មិនរំលោភបំពានលើអ្នកតូចជាងខ្លួន
- មិនចង់បានហួសពេកធ្វើការហួសកំលាំងខ្លួននាំឲ្យមានគ្រោះថ្នាក់ ឬ មានជំងឺផ្សេងៗដល់ខ្លួន ដែលនាំឲ្យខូចប្រយោជន៍ ។

**ង. សីលធម៌ចំពោះសង្គមជាតិ**

- គួរស្រលាញ់រាប់អានមនុស្សទូទៅ ។
- មិនឈ្លានពានជិវិតអ្នកដទៃ
- គួរតែគោរពសិទ្ធិគ្នាទៅវិញទៅមក ។
- មានសាមគ្គីល្អ រវាងគ្នា និង គ្នា ។
- មិនធ្វើឲ្យអ្នកដទៃរងទុក្ខដោយសារខ្លួន។
- ស្រលាញ់យុត្តិធម៌ និង សន្តិភាពសង្គម ។
- គួររស់នៅក្នុងភាពប្រុងប្រយ័ត្នគ្រប់វិនាទី ។ ដូចជាពាក្យស្លោកមួយបានពោថា "នៅម្នាក់ឯងត្រូវប្រយ័ត្នគំនិត នៅក្នុងគ្រួសារត្រូវប្រយ័ត្នទឹកមុខ នៅក្នុងសង្គមត្រូវប្រយ័ត្នសម្តី" ។
- សាលារៀនគួរតែបញ្ចូលនូវការសិក្សាសីលធម៌ទៅក្នុងកម្មវិធីសិក្សាឱ្យបានច្រើន
- លោកគ្រូ អ្នកគ្រូគួរដើរតួជាគម្រូល្អដល់យុវវ័យ ឬសិស្ស ឬនិស្សិត
- រាល់ច្បាប់ដែលបង្កើតឡើងត្រូវតែមានភាពយុត្តិធម៌ចំពោះបុគ្គលគ្រប់រូប និងប្រកបដោយក្រមសីលធម៌។
- រិតបន្តឹងច្បាប់ និង ត្រូវលុបបំបាត់អំពើពុករលួយ ស៊ីសំណូកនៅក្នុងសង្គម
- គួរតាមដានឱ្យបានល្អិតល្អន់ នូវរាល់ការផ្សព្វផ្សាយផ្សេងៗ ដូចជាទស្សនាវដ្តី កាសែត វីដេអូ វិទ្យុ និងទូរទស្សន៍ជាដើម។
- ត្រូវបង្កើតកម្មវិធីអប់រំឱ្យបានច្រើនតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- លើកទឹកចិត្តដល់អ្នកដែលបានប្រព្រឹត្តអំពើល្អ។
- គួរតាមដានត្រួតពិនិត្យ និងកែច្នៃអ្វីដែលជាវប្បធម៌បរទេសឲ្យសមស្របទៅតាមវប្បធម៌ជាតិ។

### ច. សីលធម៌ចំពោះពិភពលោក

វប្បធម៌សន្តិភាពពិភពលោក មានន័យថាមនុស្សទូទាំងពិភពលោក ត្រូវតែរស់នៅក្នុងភាពស្មើៗគ្នា មានតម្លៃដូចៗគ្នា ជាភាតរភាព ។ លោក Neal Arm Strong ជាអាកាសយានិកម្នាក់មានប្រសាសន៍ថា អនាគតមនុស្សតែមួយ ពិភពលោកតែមួយ។ ដូច្នេះវិជ្ជា និង សីលធម៌ គឺសម្បត្តិដ៏មានតម្លៃ សម្រាប់មនុស្សគ្រប់គ្នាត្រូវតែមានជាចាំបាច់ មិនអាចខ្វះណាមួយឡើយ ។ វិជ្ជា នឹង សីលធម៌ប្រៀបបានទៅនឹងស្លាបបក្សីទាំងទ្វេរ។ មនុស្សមានវិជ្ជាហើយត្រូវតែប្រកាន់យកនូវសីលធម៌បន្ថែមទៀត ដើម្បីបញ្ជាក់ពិគុណភាពនៃវិជ្ជា និងលើកកម្ពស់នូវតម្លៃនៃជីវិតឲ្យកាន់តែមានរស្មីត្រចះត្រចង់ ។ មិនតែប៉ុណ្ណោះ វិជ្ជា និង សីលធម៌ បានបញ្ជាំងអោយសង្គមជាតិទាំងមូលមានការអភិវឌ្ឍន៍ប្រកបដោយសុខសន្តិភាព។

- រាប់អានគ្នាដោយ មិនរើសអាង ឬប្រកាន់ពូជសាសន៍ សាសនា សញ្ជាតិ ពណ៌សម្បុរ......
- រួមសហការគ្នាក្នុងទិសដៅពង្រឹងវប្បធម៌ សន្តិភាព
- ដោះស្រាយបញ្ហាដោយសន្តិវិធីមិនប្រើអំពើហិង្សា
- សាមគ្គីភាព និង អន្តរជាតិ (ក្នុងប្រទេស ក្នុងតំបន់ ក្នុងពិភពលោក) ។

ទាំងអស់នេះ គឺជាភាពចាំបាច់នៃសីលធម៌ក្នុងសង្គមខ្មែរ។ ប៉ុន្តែបច្ចុប្បន្នតម្លៃនៃសីលធម៌ខ្មែរកំពុងតែស្រុតចុះគួរឲ្យព្រួយបារម្ភ។ មូលហេតុទាំងឡាយនោះ គឺបណ្តាលមកពីកត្តាមួយចំនួនដូចជា ការអូសបន្លាយនូវសង្គ្រាមជាច្រើនទសវត្ស ដែលបានធ្វើឲ្យចិត្តគំណិតស្មារតីរបស់ប្រជាជនកម្ពុជាមានការផ្លាស់ប្តូរ ហើយបញ្ហាមួយទៀតគឺ ការហូរចូលនូវវប្បធម៌ អរិយធម៌ បរទេសយ៉ាងអនាធិបតេយ្យមកលើវប្បធម៌ អរិយធម៌ខ្មែរ។ ការហូរចូលនូវមនោគមវិជ្ជាបានធ្វើឲ្យប្រជាជនខ្មែរ ជាពិសេសសម្រាប់យុវជនទទួលយកដោយពុំមានការពិចារណា។

## ៥. មូលហេតុនៃការស្រុតចុះនៃតម្លៃសីលធម៌ក្នុងសង្គមខ្មែរធ្លាក់ចុះ

ព្រះសម្មាសម្ពុទ្ធបានសំដែងថា អនិច្ចំ ទុក្ខំ អនត្តា។ **អនិច្ចំ** មានន័យថាមិនទៀងទាត់ អ្វីតែងប្រែប្រួល ហើយអ្វីៗដែលកើតឡើងហើយរមែងរលត់ផុតទៅវិញជាធម្មតា។ **ទុក្ខំ** ប្រែថាអ្វីដែលកើតឡើងមកហើយនោះ រមែងមានទុក្ខជាប់មកជាមួយជានិច្ច។ **អនត្តា** ប្រែថាមិនមែនជារបស់ខ្លួន គ្មាននរណាម្នាក់អាចគ្រប់គ្រងឬបញ្ជារ ទៅអ្វីមួយបានជារៀងរហូតនោះទេ។ រីឯសីលវិញក៏យ៉ាងនោះដែររមែងប្រែប្រួលជានិច្ច តែគ្មាននរណាម្នាក់ដែល មិនត្រូវការសីលធម៌នោះទេ តែគ្រាន់តែពេលខ្លះគេមិនអាចបង្កើតឬគ្រប់គ្រងវាអោយនៅស្ថិតស្ថេរជានិរន្តន៍បាន តែប៉ុណ្ណោះ។ យើងមានកត្តាជាច្រើនដែលធ្វើអោយសីលធម៌ធ្លាក់ចុះ ។

**ក. កត្តាមនោសញ្ចេតនាចាក់ផ្លូត់**

សកម្មភាពនេះភាគច្រើនកើតឡើងរវាងឪពុកម្តាយ និងកូន។ ដោយ សារតែការស្រលាញ់កូនតូចៗរបស់ខ្លួន ឪពុកម្តាយភាគច្រើនបង្រៀនកូនអោយចេះជេរ ឬវាយក្បាលខ្លួន ហើយខ្លួន បែរជាសើចសប្បាយជាការលេងសើចទៅវិញទាំងនេះហើយដែលធ្វើអោយកូនៗរឹតតែហ៊ានឡើងៗ ហើយ សីលធម៌ក៏ធ្លាក់ចុះ។

**ខ. ការបាត់បង់ជំនឿលើខ្លួនឯង**

ការបរាជ័យលើកិច្ចការងារ និងគោលបំណងរបស់ខ្លួនញឹកញាប់ គួបផ្សំនឹងការមិនអាចគ្រប់គ្រងចិត្តខ្លួនឯងលែងបាន ធ្វើអោយគេបាត់បង់ក្តីសង្ឃឹមក្នុងជីវិត គិតថាសង្គមអយុត្តិធម៌ ហើយគេមើលឃើញតែភាពខ្មៅងងឹតសម្រាប់ជីវិត។ ពេលខ្លះគេលែងចង់រស់ ពេលខ្លះគេលែងគិតពីអ្នកដែលនៅជុំវិញខ្លួគេក្រោយមកគេក៏សម្រេចចិត្តធ្វើសកម្មភាពផ្សេងៗដែលគេគិតថា គឺការទាមទារយុត្តិធម៌ពីសង្គមមកវិញហើយខ្លះទៀតក៏ធ្លាក់ខ្លួនជាចោរ ជាឃាតករ ឬជាមនុស្សព្រៃផ្សៃ ពេលនោះហើយដែលធ្វើអោយសីលធម៌ធ្លាក់ចុះ។

**គ. កត្តាសង្គ្រាមអូសបន្លាយ**

សង្គ្រាមញឹកញាប់នឹងអូសបន្លាយយូរពេកបានធ្វើអោយមនុស្ស ធ្លាក់ក្នុង ភាពក្រីក្រ ខ្វះជម្រកព្រាត់ប្រាស់បងប្អូន ប្រពន្ធប្តី ឪពុកម្តាយ លែងជឿទុកចិត្តគ្នាឯង ខ្វះការអប់រំ ខ្វះអាហារ ពេលនោះហើយធ្វើដែលអោយមនុស្សលែងត្រូវការសេរីភាព លែងខ្វល់ខ្វាយពីសីលធម៌ គេត្រូវការតែជុំបាយដើម្បីដាក់ក្នុងក្រពះដើម្បីតែរស់ ពេលនោះសីលធម៌ក៏ធ្លាក់ចុះ។ សេរីភាព ឬ សីលធម៌នឹងមិនស្ថិតនៅជាមួយអ្នកបានយូរទេ បើសិនក្រ ពះរបស់អ្នកកំពង់តែស្រេកឃ្លាននោះ។ វាមិនខុសពីសុភាសិតមួយបានពោលថា សុភមង្គលរបស់អ្នកនឹងផ្លោះ ចេញតាមបង្អួចនៅពេលដែលភាពក្រីក្របានមកដល់មាត់ទ្វាររបស់អ្នក។

**ឃ. កត្តាមហិច្ឆតា**

ការលោភលន់របស់មនុស្សគ្មានទីបញ្ចប់ ដូចដែលមហាត្មះ គន្ធី បានពោលថា ពិភពលោកបានបង្កើតអ្វីៗគ្រប់យ៉ាងសម្រាប់មនុស្ស តែពិភពលោកមិនអាចបង្កើតអ្វីៗគ្រប់យ៉ាងសម្រាប់មហិច្ឆតា របស់មនុស្សបានទេ។ មហិច្ឆតាបង្កើតអោយមានអ្នកមាននឹងអ្នកក្រ អ្នកប្រើគេនិងអ្នកដែលត្រូវបានគេប្រើ ពេលនោះភាពអយុត្តិធម៌ក៏កើតមានគួបផ្សំនិងការចង់បានមិនមានដែនកំណត់ របស់មនុស្សក៏បានធ្វើអោយ

សីលធម៌ធ្លាក់ចុះ។ ដូចគ្នា នេះដែរលោក ថូម៉ាស់ ហាប បានពោលថា “មនុស្សគឺជាឆ្កែចចក” គេមិនខ្លាចនឹងប្រព្រឹត្តអំពើផ្សេងៗដើម្បីបម្រើ អោយផលប្រយោជន៍ខ្លួនគេឡើយ។

**ខ. កត្តាទ្រព្យសម្បត្តិ**

នៅពេលដែលមនុស្សមានសម្ភារៈនិងទ្រព្យសម្បត្តិហូរហៀរពេកគេក៏លែងស្តាយ និង ខ្វល់ខ្វាយពីរបស់ បន្តិចបន្តួច។ គេគិតថាបើរបស់មួយខូចខាតទៅគេអាចទិញថ្មីទៀតបាន ហើយបើគេបានធ្វើអោយសម្ភារៈអ្នក ដទៃខូចខាតវិញគេនឹងអាចទិញសងវិញភ្លាម ពេលនេះហើយដែលមនុស្សបានគិតថា”មានប្រាក់គឺមានអ្វីៗទាំង អស់”។ មួយវិញទៀតដោយសារតែភាពក្រីក្រក៏បានធ្វើអោយមនុស្សលែងគិតពីសីលធម៌ផងដែរ។ ព្រោះមនុ ស្សសត្វទាំងពួងស្រលាញ់ជិវិតជាងអ្វីៗទាំងអស់គេប្រាកដជាហ៊ានធ្វើអំពើអសីលធម៌ដើម្បីរស់។

**ច. កត្តាហូរចូលនៃវប្បធម៌បរទេស**

ការប្រើប្រាស់សំភារៈទំនើបៗ បានធ្វើអោយមនុស្សកាន់តែមាននូវមហិច្ឆតា ការចម្លងនូវរបៀបរស់នៅតាមរបៀបបរទេសដែលខុសពីសង្គមជាតិរបស់ខ្លួនបានធ្វើ អោយសីលធម៌របស់សង្គមជាតិខ្លួនបាត់បង់។ ឧទាហរណ៍: ពីមុនខ្មែរតែងទទួលរាក់ទាក់គ្នាដោយទឹកតែ តែឥឡូវភាគច្រើនទទួលរាក់ទាក់គ្នាដោយសុរា ឬ គ្រឿងស្រវឹង ហើយការញ៉ាំសុរាឬគ្រឿងស្រវឹងនេះទៀតសោត ពេលខ្លះបង្ករអោយមានមិត្តភាព តែពេលខ្លះបង្កអោយមានជំលោះដោយសារស្រវឹងស្រាវង្វេងស្មារតី។

**ឆ. កត្តាច្បាប់**

ច្បាប់ត្រូវបានគេតាក់តែងឡើងដើម្បីកំនត់អំពីសិទ្ធិសេរីភាពរបស់មនុស្សក្នុងសង្គម ដើម្បីអោយសង្គមមានសណ្តាប់ធ្នាប់មានសីលធម៌ តែពេលខ្លះច្បាប់ក៏ត្រូវបានតាក់តែងឡើងដោយក្រុមអ្នកមានអំណាច ហើយ គ្រប់គ្រងនិងជិះជាន់កៀបសង្កត់អ្នកទន់ខ្សោយផងដែរ។ យើងដឹងហើយថាច្បាប់មិនមានការលើកលែងទេ អ្នក ដែលធ្វើខុសច្បាប់ត្រូវទទួលទោស ដូច្នេះច្បាប់បានកំណត់ពីសីលធម៌ មិនគោរពទៅតាមកាលៈទេសៈទេ ដូចសុភាសិតចិនបាននិយាយថា បើយល់ញាត្តិ គឺឃ្លាតច្បាប់។ ផ្ទុយមកវិញបើច្បាប់កាន់តែធ្លាក់ចុះខ្សោយក៏ជាកត្តាដែលធ្វើអោយមនុស្សកាន់តែគឃ្លើនហ៊ាន ធ្វើអំពើអបាយមុខផ្សេងដោយមិនខ្លាចទទួលទោសដែរ ដូចជាអំពើពុករលួយ ការដណ្តើមអំណាច ការជិះជាន់កេងប្រវ័ញ្ច ចោរកម្ម ឃាតកម្មជាដើម។

### ជ. កត្តាគ្រឿងញៀន

ការប្រើប្រាស់គ្រឿងញៀនបានធ្វើអោយមនុស្សវង្វេងស្មារតីលែងស្គាល់អ្វីល្អអ្វីអាក្រក់ ហ៊ានអ្វីគ្រប់បែបយ៉ាងដើម្បីបំពេញបំណងខ្លួន ដូច្នេះហើយសីលធម៌ក៏គ្មានដែរ។

### ឈ. កត្តាអប់រំធ្លាក់ចុះ

បុគ្គលដែលខ្វះនូវការអប់រំ ខ្វះនូវចំណេះវិជ្ជា ខ្វះនូវការពិចារណា ធ្វើអោយគេមិនដឹងថា តើសកម្មភាពដែលគេបានធ្វើត្រឹមត្រូវទៅតាមគន្លងសីលធម៌ដែរឬអត់ទេ។ សីលធម៌ក៏ធ្លាក់ចុះបន្តិចម្តងៗ ដោយសារតែខ្វះការអប់រំផ្នែកសីលធម៌។

នៅតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា តាមវិទ្យុ តាមកញ្ចក់ទូរទស្សន៍ ទស្សនាវដ្ដីជាដើម បានប្រើប្រា ស់នូវពាក្យសម្តីខ្វះនូវក្រមសីលធម៌ផងដែរ តែគេបែរជាគិតថាវាជាការលេងសើចសប្បាយទៅវិញ។ ទាំងនេះក៏ជាគំរូអាក្រក់ដល់ការអប់រំផ្នែកសីលធម៌ផងដែរ។

## ៦. ផលវិបាកដែលបណ្តាលពីការធ្លាក់ចុះនៃសីលធម៌

មានហេតុត្រូវមានផល នេះជាសច្ចធម៌ដែលសម្តែងឡើងដោយព្រះសម្មាសម្ពុទ្ធនៃយើង។ យ៉ាងណាមិញសីលធម៌ក៏ដូច្នេះដែរ បើកាលណាសីលធម៌ដែលជាសេចក្តីល្អបានរុះរោយធ្លាក់ចុះហើយរមែងបាន នូវលទ្ធផលអាក្រក់ឬសេចក្តីអាក្រក់កើតឡើងយ៉ាងនោះដែរ។ ផលវិបាកទាំងនោះមានដូចខាងក្រោមនេះ ៖

### ក. ការបាត់បង់នូវសេចក្តីសុខខាងផ្លូវចិត្ត

តើសេចក្តីសុខនឹងកើតមានឡើងម្តេចបាន បើខ្លួនអ្នកនឹងសង្គមដែលអ្នកកំពុងរស់នៅពោរពេញដោយក្តីអសប្បុរស គ្មានធម៌មេត្តាករុណា ឬគ្មានព្រហ្មវិហារធម៌នៅក្នុងខ្លួន មានតែភាពច្រណែនឈ្នានីសមានតែភាពលោភលន់។ ព្រះសាស្តាបានសម្តែងថាមានរូបគឺមានទុក្ខ សេចក្តីទុក្ខកើតមានឡើងដោយអវិជ្ជា និង តណ្ហា ឬ លោភៈ ទោសៈ និង មោហៈ។ អ្នកនឹងមិនបានសុខទេបើចិត្តរបស់អ្នកនៅតែចង់បានឥតឈប់ឈរ។

### ខ. បាត់បង់គុណតម្លៃជាមនុស្ស

ដរាបណាមនុស្សគ្មានវិន័យ គ្មានច្បាប់ គ្មាសីលធម៌នៅក្នុងខ្លួនទេ មិនខុសអ្វីពីសត្វធាតុដែលគ្មាននូវពិចារណាញាណនោះទេ ហើយសង្គមនោះក៏មិនខុសពីសង្គមសត្វដែរ។ ពួកគេលួច ឆក់ ប្លន់ កាប់សម្លាប់គ្នា

ដោយគ្មានញរញើត ហើយចាត់ទុករឿងទាំងនេះជាល្បែងកំសាន្តទៀតផង ដែលគេនិយមហៅថាជាសណ្ដានមនុស្សព្រៃ ឬសត្វព្រៃ ឬសត្វតិរច្ឆាន។

**គ. បែកបាក់សាមគ្គី**

យើងដឹងហើយថាសីលធម៌បានតាក់តែងមនុស្សអោយចេះរស់នៅជាមួយគ្នាដោយសេចក្ដីសុខ តែបើបើពួកគេលែងមានសីលធម៌ហើយ លែងទុកចិត្តគ្នាទៀតហើយ នោះពួកគេនឹងព្យាយាមផ្ដាច់ខ្លួនចេញពីគ្នាដើម្បី ស្វែងរកទីដែលគេគិតថាផ្ដល់សេចក្ដីសុខដល់ខ្លួនគេ។

**ឃ. អសន្តិសុខសង្គម**

សង្គមមួយដែលសម្បូរដោយចោរកម្ម មានអំពើហិង្សាផ្សេងៗ ដែលកើតឡើងដោយពពួកមនុស្សល្ងង់ ខ្លៅ អសីលធម៌ រួមផ្សំជាមួយនិងប្រព័ន្ធច្បាប់ធូររលុង នោះសមាជិកនៅក្នុងសង្គមប្រាកដជាមិនអាចរស់នៅ ដោយសេចក្ដីសុខនោះទេ ពួកគេម្នាក់ៗប្រាកដជារស់នៅដោយភាពភ័យខ្លាចគ្រប់វិនាទី។

**ង. សង្គ្រាម**

មហិច្ឆតាដែលគ្មានដែនកំណត់របស់មនុស្ស រួមផ្សំនិងការឥតមានសីលធម៌គ្របដណ្ដប់នឹងបណ្ដាលមានភាពច្រណែនគ្នា ចង់បានរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ដូចដែលព្រះជិនស្រីបានសម្ដែងថា ទោះបីមានភ្នំ មាសពីរក៏មិនល្មមគ្រប់គ្រាន់សម្រាប់តណ្ហារបស់មនុស្សម្នាក់ដែរប្រាកដជាទៅដណ្ដើមភ្នំមាសអ្នកដទៃជាមិនខាន ។ ទីណាមានការគាបសង្កត់ មានការជិះជាន់ ទីនោះប្រាកដជាមានការរើបម្រាស់ គ្មាននរណាម្នាក់អង្គុយចាំឲ្យ គេមកយករបស់ដែលជាទីស្រលាញ់ដោយងាយៗ ឬ អង្គុយចាំអោយគេមកជេរប្រមាថ កាប់សម្លាប់ដោយងាយ ៗនោះដែរ គេប្រាកដជាក្រោកបះបោរតស៊ូរមែនទីបញ្ចប់ ដូចនេះសង្គ្រាមក៏បានផ្ទុះឡើងដោយសារតែការមិនចេះយោគយល់គ្នា លោភលន់ឥតទីបញ្ចប់។

## ៧. ដំណោះស្រាយខ្លះៗក្នុងការលើកកម្ពស់សីលធម៌

ឈរលើទស្សនៈថា បញ្ហាអ្វីក៏មានដំណោះស្រាយ បញ្ហាអ្វីក៏អាចដោះស្រាយបាន។យើងក៏អាចនិយាយបានថា សីលធម៌ដែលធ្លាក់ចុះក៏អាចស្រោចស្រង់វិញបានដែរ។ ខាងក្រោមនេះជាមធ្យោបាយខ្លះៗក្នុងការរួមចំណែកលើកកម្ពស់សីលធម៌ឡើងវិញ ៖

### ក. ផ្តើមពីបុគ្គលខ្លួនឯង

ការស្គាល់ពីខ្លួនឯង ការព្យាយាមគ្រប់គ្រងខ្លួនឯងជាបញ្ហាចម្បងដែលធ្វើអោយយើងស្គាល់និងយល់ពី សណ្ដានចិត្តរបស់អ្នកដទៃ។ សូក្រាតបានពោលថា ដើម្បីអោយមានសីលធម៌ មនុស្សម្នាក់ៗត្រូវស្គាល់ខ្លួនឯង ជាមុនសិន។ ការស្គាល់ខ្លួនឯងមិនគ្រាន់តែស្គាល់ត្រឹមឈ្មោះ ដើមកំណើត អាយុ ភេទ ប៉ុណ្ណឹងនោះទេ គឺត្រូវ ស្គាល់ចំនុចខ្លាំង ចំនុចខ្សោយរបស់ខ្លួន ហើយខ្លួនកំពុងនៅទីណា ស្គាល់ពីចិត្តខ្លួនឯងត្រូវការអ្វី ស្រលាញ់អ្វី ស្អប់អ្វីផងដែរ។

បុគ្គលគ្រប់រូបត្រូវស្គាល់ពីតួនាទីរបស់ខ្លួននិងធ្វើខ្លួនអោយល្អប្រពៃតាមតួនាទី ដូចជាធ្វើកូនល្អក្នុងគ្រួសារ សិស្សល្អក្នុងសាលារៀន ពលរដ្ឋល្អក្នុងសង្គម បុគ្គលិកល្អក្នុងក្រុមហ៊ុនជាដើម។

### ខ. ការស្គាល់ពីគុណតម្លៃខ្លួនឯងនឹងអ្នកដទៃ

មនុស្សត្រូវការការផ្តល់តម្លៃ ការគោរពរាប់អាន ដូច្នេះបើខ្លួនអ្នកត្រូវការអោយអ្នកដទៃអោយតម្លៃវិជ្ជមានមកលើអ្នក គោរពស្រលាញ់អ្នក លុះត្រាអ្នកអោយតម្លៃវិជ្ជាមាន គោរពស្រលាញ់អ្នកដទៃវិញដែរ។ ខុង ជឺ បាននិយាយថា បើអ្នកចង់អោយអ្នកដទៃធ្វើអំពើល្អមកលើខ្លួននោះ លុះត្រាតែអ្នកធ្វើអំពើល្អទៅគេផងដែរ។

បុគ្គលគ្រប់រូបត្រូវចេះ ជួយទុក្ខធុរៈគ្នា ស្មោះត្រង់ចំពោះគ្នានិងគ្នា ចែករំលែកផលប្រយោជន៍គ្នាតាមសម គួរ មានទឹកចិត្តរីករាយជាប្រចាំ មានព្រហ្មវិហារធម៌ គឺមេត្តា ករុណា មុទិតា និង ឧបេក្ខាចំពោះគ្នាទៅវិញទៅ មក យល់ថា “បើចង់អោយអ្នកដទៃគោរពខ្លួនយ៉ាងណា អ្នកត្រូវគោរពអ្នកដទៃយ៉ាងនោះ”។

### គ. លើកទឹកចិត្តសកម្មភាពសីលធម៌

គ្មានបុគ្គលណាម្នាក់ដែលមិនត្រូវការការកោតសរសើរនោះទេ នេះជាតម្រូវការមួយក្នុងចំណោមតំរូវការទាំងប្រាំដែលលោក ម៉ាស្លូបានលើកឡើង ដែលយើងហៅថាតម្រូវការម៉ាស្លូមាន តម្រូវការផ្នែកសារពាង្គកាយ តម្រូវការផ្នែកសុវត្ថិភាព តម្រូវការសង្គមគឺការស្រលាញ់ តម្រូវការការអោយតម្លៃនិងការគោរព និងតម្រូវការ កិត្តិយសផ្ទាល់ខ្លួន។ ដូចនេះបើយើងអោយតម្លៃខ្ពស់ និងលើកសរសើរដល់អ្នកដែលបានធ្វើនូវសកម្មភាពសីល ធម៌នោះៗពួកគេនឹងព្យាយាមធ្វើសកម្មភាពទាំងនេះកាន់តែខ្លាំងឡើង។ ដូចជាសកម្មភាពជួយទុក្ខធុរៈគ្នា ចែករំលែកនូវសម្ភារៈប្រើប្រាស់ ទ្រព្យសម្បត្តិ ចំណេះដឹងផ្សេងៗ យើងក៏គួរផ្តល់អោយពួកគេនូវ រង្វាន់ ឬ ពានរង្វាន់ ទៅតាមអ្វីដែលពួកគេរីករាយនឹងទទួលយក។

ព្រះសម្មាសម្ពុទ្ធបានសម្តែងថា យើងត្រូវតបស្នងសងគុណដល់អ្នកដែលបានធ្វើគុណមកលើយើង។ នេះក៏ជាកត្តាដែលធ្វើអោយមនុស្សចេះអធ្យាស្រ័យគ្នា និង ធ្វើឲ្យសកម្មភាពសីលធម៌កាន់តែមានភាពរស់រវើកឡើង។ ចំពោះ **សូក្រាត** យល់ថា **ការគ្រប់គ្រងដោយសីលធម៌ ប្រសើរជាងការគ្រប់គ្រងដោយច្បាប់។**

**ឃ. បង្កើនការអប់រំផ្នែកសីលធម៌**

បច្ចេកវិទ្យាកាន់តែខ្ពស់ធ្វើឲ្យមនុស្សកាត់បន្ថយជំនឿទៅលើ សាសនាដែលបង្កប់ទៅដោយខ្លឹមសារទស្សនវិជ្ជាដែលធ្វើអោយមនុស្សមានសីលធម៌ តែពួកគេគួរដឹងដែរថាបើកាលណាវិទ្យាសាស្ត្រមិនមានសីលធម៌នោះវានឹងបង្ហាញសង្គមមនុស្សទៅវិញទេ។ ដូចនេះសង្គមគួរយកចិត្តទុកដាក់អប់រំបង្រៀនអោយមនុស្សដែលមិន បានដឹងបានស្គាល់ អោយបានដឹងបានស្គាល់បានយល់ពីតម្លៃរបស់សីលធម៌។ រីឯការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ក៏ជាកត្តារួមចំណែកដល់ការអប់រំផ្នែកសីលធម៌ដែរ ដូចនេះយើងគួរផ្សព្វផ្សាយផ្នែកសីលធម៌ និងប្រើប្រាស់នូវភាសាប្រកបដោយសីលធម៌អោយបានច្រើន ជាជាងការជេរប្រទេចគ្នា ឬយកសីលធម៌ធ្វើជារឿងកម្លែង សម្រាប់សើចកំសាន្ត។ ការអប់រំក៏ជាកត្តាទប់ស្កាត់មនុស្សអោយអណ្តែតត្រសែតទៅតាមមនោសញ្ចេតនា ឬភាពអស់សង្ឃឹម ឬបាក់ទឹកចិត្តបានដែរ គឺការគ្រប់គ្រងអារម្មណ៍ខ្លួនឯង។

**ង. ការបណ្តុះគំនិតជាតិនិយម**

ជាតិនិយម ជាទ្រឹស្តីមួយអប់រំអោយស្រលាញ់ជាតិរបស់ខ្លួន ស្រលាញ់ប្រទេស ស្រលាញ់ប្រវត្តិសាស្ត្រ និងមានគំនិតកសាងប្រទេសជាតិរបស់ខ្លួនឲ្យទៅជារដ្ឋត្រឹមត្រូវសម្បូរសប្បាយ។ ថ្វីត្បិតតែមនុស្សគ្រប់រូបរមែងគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនក៏ពិតមែន តែបើគេមានជាតិនិយមក្នុងខ្លួន គេនឹងស្រលាញ់សង្គមជាតិរបស់គេ និងចង់អោយពិភពលោកទាំងមូលរស់នៅក្នុងសុខសន្តិភាព។

**ច. សន្តិភាពក្នុងចិត្ត**

សន្តិភាពគឺ សេចក្តីស្ងប់ សេចក្តីស្រលាញ់ ចិត្តមេត្តាករុណា អធ្យាស្រ័យយុត្តិធម៌ និងសេចក្តីថ្លៃថ្នូរគ្មានសង្គ្រាម... ។ ដើម្បីអោយមនុស្ស ឬ សង្គមមានសន្តិភាព និង អាចស្ថិតស្ថេរបានលុះត្រាតែមានការគោរព សិទ្ធិ ការអត់ឱន ការអធ្យាស្រ័យ ទំនាក់ទំនងល្អជាមួយអ្នកដទៃ មានយុត្តិធម៌ និងប្រជាធិបតេយ្យ។

### ឆ. វិតបន្ដឹងច្បាប់

បើសិនជាច្បាប់នោះបង្កើតឡើងដោយប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋនោះ ច្បាប់ត្រូវតែបានអនុវត្តន៍ទៅលើគ្រប់បុគ្គលទាំងអស់ដោយស្មើរភាពគ្នា។ **អារីស្តូត** បានពោលថាប្រទេសមួយដែលរឹងមាំមានស្ថេរភាពមានការីកចម្រើនគឺអាស្រ័យច្បាប់ហើយច្បាប់នោះត្រូវតែមានសមភាព ចំពោះប្រជាពលរដ្ឋទាំងអស់។ដូចនេះបើកាលណាច្បាប់មិនមានភាពធូរលុងទេហើយនឹងដាក់ទោសស្មើរគ្នាចំពោះអ្នកដែលប្រព្រឹត្តខុសនោះៗនឹងធ្វើអោយមនុស្សខ្លាចរអារមិនហ៊ានប្រព្រឹត្តអំពើឆ្គាំឆ្គងដែលខុសសីលធម៌នោះឡើយ។

## ៨. សេចក្តីសន្និដ្ឋាន និង អនុសាសន៍

### ក. សេចក្តីសន្និដ្ឋាន

រហូតមកដល់ពេលនេះ ការអប់រំនៅតែបន្តតួនាទីយ៉ាងសំខាន់ ក្នុងការបណ្តុះបណ្តាលសង្គមខ្មែរ ដើម្បីទប់ស្កាត់ការហូរចូលនៃវប្បធម៌បរទេសខាងក្រៅ ដែលបានធ្វើឲ្យយុវជនលង់លក់ បាត់គុណធម៌ ប្រពៃណីធ្លាក់ចុះអន់ថយ។ នៅក្នុងសង្គមខ្មែរយើង ដោយសារតែបុគ្គលមួយចំនួនខ្វះសីលធម៌ ទើបធ្វើឲ្យសង្គមជួបបញ្ហាជាច្រើន។ ដូចនេះដើម្បីស្តារឡើងវិញនូវកត្តាអសកម្ម ប្រជាពលរដ្ឋខ្មែរត្រូវរួបរួមគ្នា កំចាត់នូវវប្បធម៌ហិង្សា ជាពិសេសបណ្តុះបណ្តាលកុលបុត្រកុលធីតាខ្មែរឲ្យស្រលាញ់វប្បធម៌ មានសីលធម៌ គុណធម៌ អប់រំឲ្យពលរដ្ឋមានសីលធម៌ចំពោះខ្លួនឯងផង និង សង្គមជាតិផង ព្រោះថាសីលធម៌អាចដឹកនាំមនុស្សឲ្យដើរតាមមាគ៌ាមួយឆ្ពោះទៅរកសេចក្តីសុខចំរើន ចៀសវាងអំពើអមនុស្សធម៌ ហិង្សា អំពើពុករលួយ ការប្រកាន់វណ្ណៈ.....។ ស្របទៅនឹងការខិតខំរបស់ពលរដ្ឋខ្មែរ យើងសង្ឃឹមថាវប្បធម៌បរទេសមិនជះផលអាក្រក់ទៅលើវប្បធម៌ខ្មែរទៀតទេ ហើយប្រទេសជាតិងាកទៅរកការបណ្តុះបណ្តាលវប្បធម៌សន្តិភាព និងការអប់រំសីលធម៌ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើន ដូចអរិយប្រទេសនៅលើពិភពលោក។ យើងឃើញថាសីលធម៌ គឺជាបញ្ហាចម្បងដែលសង្គមគួរយកចិត្តទុកដាក់ ព្រោះសង្គមដែលគ្មានសីលធម៌ មិនខុសអ្វីពីសង្គមសត្វតិរច្ឆាននោះទេ ឬ ជួនកាលអន់ជាងសត្វតិរច្ឆានទៅទៀត។ សីលធម៌មានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាសីលធម៌នឹងធ្វើអោយមនុស្សគ្រប់រូបមានសេចក្តីថ្លៃថ្នូរ មានសេចក្តីសុខទាំងកាយវាចារចិត្ត មានសន្តិភាព សុវត្ថិភាព មានការអភិវឌ្ឍន៍ ។ លោក **នៃល អាំស្ត្រង** បាននិយាយថា អនាគតពិភពលោកតែមួយមនុស្សតែមួយ មានន័យថាសង្គមទាំងអស់នៅលើពិភពលោកទាំងមូល នឹងរស់នៅជាមួយគ្នាដូចជាគ្រួសារតែមួយ។ ទោះបីយ៉ាងណាក៏ដោយ ទ្រឹស្តីនេះអាចទៅរួចលុះត្រាតែ សង្គមទាំងមូលឈរនៅលើសន្តិភាពនិយម ចេះជួយគ្នាគឺមានព្រហ្មវិហារធម៌ចំពោះគ្នា។

ដោយយល់ពីតម្លៃរបស់របស់សីលធម៌ និងចង់ឲ្យសីលធម៌ស្ថិតនៅគង់វង្ស មានការរីកចម្រើន យើងគួរតែនាំគ្នាធ្វើអំពើល្អ ដែលជាអំពើសីលធម៌ចាប់ពីពេលនេះតទៅ យើងនាំគ្នាអោយតម្លៃសកម្មភាពណាដែលជា សកម្មភាពសីលធម៌ អប់រំក្មេងៗឬអ្នកដែលមិនដឹងមិនយល់អោយដឹងអោយយល់អោយអនុវត្ត។ យើងនាំគ្នាផ្សព្វផ្សាយកម្មវិធីផ្សេងៗដែលមានប្រយោជន៍និងប្រកបដោយសីលធម៌។ ជាងនេះទៅទៀត យើងគ្រប់ៗរូបគួរ នាំគ្នាគោរពច្បាប់រដ្ឋ ថែរក្សាប្រពៃណីល្អ កែច្នៃទស្សនៈផ្សេងៗដែលហូរចូលពីបរទេសអោយសមស្របតាមការ និយមរបស់ខ្មែរ។

**ខ. អនុសាសន៍**

យើងឃើញថាប្រទេសកម្ពុជា ជាប្រទេសធ្លាប់មានប្រវត្តិសាស្ត្រ វប្បធម៌រុងរឿង ជាជនជាតិឧស្សាហ៍ព្យាយាម មានចរិតល្អសុភាពរាបសារ និង មានកេរ្តិ៍ឈ្មោះល្បីរន្ទឺលើឆាកអន្តរជាតិ យើងសង្ឃឹមថាកម្ពុជានឹងដើរតាមនូវអ្វីដែលល្អដែលប្រវត្តិសាស្ត្រធ្លាប់មានរួចមកហើយ។ ដូច្នេះក្នុងនាមយើងជាយុវជនខ្មែរ ជាសសរទ្រូងជាតិ ត្រូវមានឧត្តមគតិជាតិខ្ពស់ស្នេហា នឹងការពារវប្បធម៌ខ្លួនដែលដូនតាបានបន្សល់ទុកឲ្យជាកេរតំណែល ជាព្រលឹងជាតិរបស់ប្រជាជនខ្មែរគ្រប់រូបកុំឲ្យបាត់បង់ ដូចពាក្យស្លោកមួយបានលើកឡើងថា " **វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន** " ។

# ឯកសារយោង


- ង៉ែត សារឿន: (២០១១)ទស្សនវិជ្ជាសីលធម៌ សីលធម៌អប់រំ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា។
- ឈុន ណារ៉េត (២០០៣) វិទ្យាសាស្ត្រនយោបាយ និង ប្រវត្តិគំនិតនយោបាយ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- រុន ពណ្ណារិទ្ធ (២០០៨) ប្រវត្តិគំនិតនយោបាយ សកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លី រតនា (២០១០) ការគ្រប់គ្រង សាកលវិទ្យាល័យឯកទេសនៃកម្ពុជា។
- «សីលធម៌សំខាន់សំរាប់មនុស្ស» រៀបរៀងដោយ បណ្ឌិត ឌិត ប៉ែន ព.ស ២៥៥១។
- «សីលធម៌និងគោលធម៌ទ្រទ្រង់មនុស្សជាតិ» បោះពុម្ពលើកទី១ នៅរោងពុម្ពក្រសួងអប់រំ ព.ស ២៥៤០ គ.ស ឆ្នាំ ១៩៩៦ ដោយ យ៉ុង ហ៊ី អតីតអធីការបឋមសិក្សា។
- វចនានុក្រមខ្មែរ របស់សម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត** ដែលមាន១៨៨៨ទំព័រ។
- ម៉ុក សុវណ្ណា, រៀបរៀង, ឯកសារផ្សព្វផ្សាយស្ដីពី សីលធម៌ និង ការអភិវឌ្ឍ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តតាកែវ (ភ្នំពេញ៖ ២០០៩)។
- ស្រង់ចេញពីសៀវភៅ អត្ថាធិប្បាយទស្សនវិជ្ជា សរ សារុន ឆ្នាំ១៩៧៣។
- សៀវភៅ វប្បធម៌ទូទៅ (លោក ភុក ប៉ារ)។
- សៀវភៅ វប្បធម៌ទូទៅ (លោក មេង ហោង និង ញឹម បាក់ងន)
- សៀវភៅ សញ្ញាណទស្សនវិជ្ជា (In Virakcheat)